ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ១៤ កើត ខែចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣*

# សេចក្តីជូនដំណឹងសម្រាប់ប្រព័ន្ធសារព័ត៌មាន
## ស្តីពីជំនួបសម្តែងការគួរសម រវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ ឯកឧត្តមបណ្ឌិត PARK Jung-Wook ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ថ្មី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និង ពិភាក្សាការងារក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-សាធារណរដ្ឋកូរ៉េ ជាមួយឯកឧត្តមបណ្ឌិត PARK Jung-Wook ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពថ្មី នៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងអបអរសាទរ ចំពោះឯកឧត្តមបណ្ឌិត PARK Jung-Wook ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋកូរ៉េ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋ កូរ៉េ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងដំណើរការកសាងសន្តិភាព ស្តារ ក៏ដូចជា ចូលរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ (Official Development Assistance - ODA) និងការវិនិយោគផ្ទាល់ពីប្រទេសកូរ៉េនៅព្រះរាជាណាចក្រកម្ពុជា ។

គិតចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២០២២, ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង មានចំនួនប្រមាណ ៤៥៥ លានដុល្លារអាមេរិក និង ក្នុងក្របខ័ណ្ឌឥណទានសម្បទាន គិតចាប់ពី ឆ្នាំ ២០០១ មកដល់ដំណាច់ឆ្នាំ ២០២២ ភាគីកូរ៉េ បានសន្យា (Commitments) ផ្តល់ឥណទានសម្បទាន មានទឹកប្រាក់សរុបប្រមាណជា **១ ៨០០ លានដុល្លារអាមេរិក** ។ ចេញពីការសន្យានេះ, មានកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ៣២ កិច្ចព្រមព្រៀង បានចុះហត្ថលេខា ដែលមានទឹកប្រាក់សរុប **១ ៦០០ លានដុល្លារអាមេរិក** សម្រាប់ហិរញ្ញប្បទានដល់គម្រោងអភិវឌ្ឍន៍ និងកម្មវិធី ចំនួន ២៩ ។

ឆ្លៀតក្នុងឱកាសនេះដែរ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ដែលបានសម្រេចផ្តល់នូវការសន្យាស្តីពីការផ្តល់ឥណទានបន្តទៀត តាមរយៈកិច្ចសម្របសម្រួលក្របខ័ណ្ឌថ្មី (New Framework Arrangement) ដែលមានទំហំទឹកប្រាក់ឥណទានចំនួន **១ ៥០០ លានដុល្លារអាមេរិក** សម្រាប់ឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៦ ដែលផ្តោតបេក្ខភាពគម្រោងលើគម្រោងអភិវឌ្ឍន៍ស្របតាមវិស័យអាទិភាពសំខាន់ៗ និងស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាមួយគ្នានេះ, ភាគីទាំងពីរក៏បានពិភាក្សា អំពីគម្រោងអភិវឌ្ឍន៍ដែលមានភាពប្រឡាក់ក្រឡាជាមួយនឹងគម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ (Cambodia- Korea Friendship Bridge) ក៏ដូចជាការចូលរួមអភិវឌ្ឍន៍គម្រោងវិនិយោគនានាពីវិស័យឯកជន ផងដែរ ។

ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានសម្តែងនូវការកោតសសើរ ចំពោះលំហូរទុន និងទំហំនៃការវិនិយោគឯកជនពីប្រទេសកូរ៉េខាងត្បូង មានការកើនឡើងជាបន្តបន្ទាប់ និងបន្តស្វាគមន៍អ្នកវិនិយោគទុនពីប្រទេសកូរ៉េឱ្យបានច្រើនបន្ថែមទៀត ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (FTA) ដែលទើបតែចូលជាធរមានកាលពីដើមខែ ធ្នូ ឆ្នាំ ២០២២ នឹងជួយបង្កើនទំហំពាណិជ្ជកម្មនៃការនាំចេញ-នាំចូលរវាងប្រទេសទាំងពីរឱ្យកាន់តែមានភាពល្អប្រសើរ និងតាមរយៈកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) រវាងកម្ពុជា-កូរ៉េ ក៏នឹងជាឧបករណ៍សម្រាប់ជួយបង្កបរិយាកាសនៃការវិនិយោគពីប្រទេសកូរ៉េ ឱ្យកាន់តែមានភាពល្អប្រសើរ និងទាក់ទាញវិនិយោគិនឱ្យមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ជាក់ស្តែង, ថ្មីៗនេះ ក្រុមហ៊ុនធំៗរបស់កូរ៉េ បានមកបណ្តាក់ទុនវិនិយោគបង្កើតរោងចក្របង្គុំរថយន្តម៉ាកល្បីៗនៅប្រទេសកម្ពុជា ផងដែរ ។

ឯកឧត្តមបណ្ឌិត PARK Jung-Wook ក៏បានគូសបញ្ជាក់ជូនថា ក្នុងអាណត្តិបំពេញភារកិច្ចការទូតនេះ ឯកឧត្តមនឹងបន្តខិតខំពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបន្តការគាំទ្រនូវការផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង, ឥណទានសម្បទាន, ជំនួយបច្ចេកទេស និងកម្មវិធីចែករំលែកចំណេះដឹង ជាពិសេស ជំរុញការអភិវឌ្ឍវិស័យឯកជននានា ឱ្យកាន់តែរីកចំរើនបន្ថែមទៀត ។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏សូមជូនពរ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ឱ្យទទួលបាននូវជោគជ័យគ្រប់ភារកិច្ចក្នុងបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ដើម្បីបន្តពង្រឹង និងពង្រីកទំនាក់ទំនងសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរថែមទៀត ។